# ការរំលឹកសម្រាប់ក្មេងជំទង់ដែលដល់អាយុ 18 ឆ្នាំ

សូមប្រាប់ដំណឹងនេះឱ្យបានឆាប់រហ័សដល់កូនរបស់លោកអ្នកដែលនឹងចូលដល់អាយុ 18 ឆ្នាំក្នុងរយៈ 60 ថ្ងៃខាងមុខនេះ។

## បើអ្នកដល់អាយុ 18 ឆ្នាំ ហើយមិនមានកូន និង/ឬមិនមានផ្ទៃពោះ

អ្នកនៅតែអាចទទួលជំនួយសាច់ប្រាក់ជាផ្នែកនៃសំណុំរឿងឪពុកម្តាយ/អ្នកមើលថែរបស់អ្នកបន្ទាប់ពីថ្ងៃខួបកំណើតអាយុ 18 ឆ្នាំរបស់អ្នកបានលុះត្រាតែអ្

- ជាសិស្សរៀនពេញម៉ោងនៅវិទ្យាល័យ ឬនៅក្នុង កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ឬបច្ចេកទេស និង រំពឹងថានឹងបញ្ចប់ការសិក្សា/កម្មវិធី មុនពេល ចូលដល់អាយុ 19 ឆ្នាំ ឬ
- ជាសិស្សរៀនពេញម៉ោងនៅវិទ្យាល័យ ឬនៅក្នុង កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ឬបច្ចេកទេស និង ធ្លាប់ ឬត្រូវបានចាត់ទុកថាពិការ ហើយ ជួបតាមលក្ខណៈវិនិច្ឆ័យពិការភាព ដោយយោងតាម បទបញ្ញត្តិរបស់កម្មវិធី CalWORKs ឬ
- ជាកូនចិញ្ចឹមដែលរស់នៅជាមួយញាតិដែលប្រកាសដោយតុលាការ ហើយកំពុងរៀនបញ្ចប់កម្រិតវិទ្យាល័យ ឬកម្មវិធីសមមូល ឬចុះឈ្មោះចូលរៀននៅកម្រិតក្រោយមធ្យមសិក្សា ឬសាលាវិជ្ជាជីវៈ ឬចូលរួមក្នុងកម្មវិធី ឬសកម្មភាពដែលលើកកម្ពស់ ឬដកចេញនូវឧបសគ្គក្នុងវិស័យការងារ ឬធ្វើការយ៉ាងតិចណាស់ 80 ម៉ោងក្នុងមួយខែ ឬ មិនអាចចូលរៀននៅសាលា ឬធ្វើការបាន ដោយសារ ស្ថានភាពវេជ្ជសាស្ត្រដែលបានកត់ត្រាទុក។

ទូរស័ព្ទទៅបុគ្គលិកខោនធីរបស់អ្នកឱ្យបានឆាប់រហ័ស បើអ្នកគិតថា អ្នកជួបតាមស្ថានភាពណាមួយនៃស្ថានភាពទាំងនេះ។ បើអ្នកមានលក្ខណ សម្បត្តិទទួលបន្តទទួលជំនួយលុយសុទ្ធ នោះអ្នកអាចតម្រូវឱ្យផ្តិតម្រាមដៃ និងថតរូបថតដោយខោនធី។

## បើអ្នកដល់អាយុ 18 ឆ្នាំ ហើយមានកូនផ្ទាល់ខ្លួន និង/ឬមានផ្ទៃពោះ

1. អ្នកនៅតែបន្តទទួលជំនួយសាច់ប្រាក់ជាផ្នែកនៃសំណុំរឿងឪពុកម្តាយ/អ្នកមើលថែរបស់អ្នកបន្ទាប់ពីថ្ងៃខួបកំណើតអាយុ 18 ឆ្នាំរបស់អ្នកបានលុះត្រាតែអ្នកៈ

- ជាសិស្សរៀនពេញម៉ោងនៅវិទ្យាល័យ ឬនៅក្នុង កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ឬបច្ចេកទេស និង រំពឹងថានឹងបញ្ចប់ការសិក្សា/កម្មវិធី មុនពេល ចូលដល់អាយុ 19 ឆ្នាំ ឬ
- ជាសិស្សរៀនពេញម៉ោងនៅវិទ្យាល័យ ឬនៅក្នុង កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និង ធ្លាប់ ឬត្រូវបានចាត់ទុកថាពិការ ហើយ ជួបតាមលក្ខណៈវិនិច្ឆ័យពិការភាព ដោយយោងតាម បទបញ្ញត្តិរបស់កម្មវិធី CalWORKs ឬ
- ជាកូនចិញ្ចឹមដែលរស់នៅជាមួយញាតិដែលប្រកាសដោយតុលាការ ហើយកំពុងរៀនបញ្ចប់កម្រិតវិទ្យាល័យ ឬកម្មវិធីសមមូល ឬចុះឈ្មោះចូលរៀននៅកម្រិតក្រោយមធ្យមសិក្សា ឬសាលាវិជ្ជាជីវៈ ឬចូលរួមក្នុងកម្មវិធី ឬសកម្មភាព ដែលលើកកម្ពស់ ឬដកចេញនូវឧបសគ្គក្នុងវិស័យការងារ ឬធ្វើការយ៉ាងតិចណាស់ 80 ម៉ោងក្នុងមួយខែ ឬមិនអាច ចូលរៀននៅសាលា ឬធ្វើការបាន ដោយសារ ស្ថានភាពវេជ្ជសាស្ត្រដែលបានកត់ត្រាទុក។
- បើអ្នកមានអាយុ 18 ឆ្នាំ ហើយមានផ្ទៃពោះ ហើយមិនមានកូនផ្សេងទៀតទេ នោះអ្នកអាចទទួលបានជំនួយសាច់ប្រាក់នៅពេលណាគត៌របស់អ្នកត្រូវបានបញ្ជាក់ បើពុំនោះទេ អ្នកមានលក្ខណសម្បត្តិសម្រាប់កម្មវិធី Cal-Learn។

- ឬ -

2. អ្នកអាចជ្រើសរើសដោយចាប់ផ្តើមពីករណីខ្លួនអ្នកផ្ទាល់។ សូមទូរស័ព្ទទៅបុគ្គលិកខោនធីរបស់អ្នកឱ្យបានឆាប់រហ័ស បើអ្នកចង់ចាប់ផ្តើមសំណុំរឿងខ្លួនអ្នកផ្ទាល់។ នេះគឺជាចំណុចមួយចំនួនដែលអ្នកត្រូវដឹង នៅមុនពេលអ្នកចាប់ផ្តើមករណីខ្លួនអ្នកផ្ទាល់ៈ

- អ្នកមិនបាច់ចាកចេញពី ផ្ទះឪពុកម្តាយ/អ្នកមើលថែរបស់អ្នក ដើម្បីបង្កើតជា ករណីខ្លួនអ្នកផ្ទាល់ទេ។
- ពេលវេលាកម្រិតរបស់អ្នកចំពោះការទទួលបានជំនួយសាច់ប្រាក់ នឹងចាប់ផ្តើម។
- ក្នុងនាមជាអ្នកទទួលខុសត្រូវចំពោះករណីរបស់អ្នក អ្នកត្រូវរាយការណ៍នូវរាល់គ្រប់ ការផ្លាស់ប្តូរទាំងអស់ទៅបុគ្គលិកខោនធីរបស់អ្នក។
- បើអ្នកចាប់ផ្តើមពីករណីខ្លួនអ្នកផ្ទាល់ នោះឪពុកម្តាយ ឬអ្នកមើលថែរបស់អ្នកអាចទទួលបានជំនួយសាច់ប្រាក់តិច ឬបើលោកអ្នកជាកូនទោល នោះជំនួយសាច់ប្រាក់របស់ពួកគាត់អាចត្រូវបានបញ្ឈប់។
- បើអ្នកមានអាយុ 18 ឆ្នាំ ហើយមានផ្ទៃពោះ ហើយមិនមានកូនផ្សេងទៀតទេ នោះអ្នកអាចទទួលបានជំនួយសាច់ប្រាក់នៅពេលណាគត៌របស់អ្នកត្រូវបានបញ្ជាក់ បើពុំនោះទេ អ្នកមានលក្ខណសម្បត្តិសម្រាប់កម្មវិធី Cal-Learn។

បើអ្នកស្ថិតនៅក្នុងករណីខ្លួនអ្នកផ្ទាល់ ឬជាផ្នែកមួយនៃករណីឪពុកម្តាយ/អ្នកមើលថែ ដើម្បីមានលក្ខណសម្បត្តិបន្តទទួលជំនួយសាច់ប្រាក់ អ្នកអាចតម្រូវឱ្យផ្តិតម្រាមដៃ និងថតរូបថតដោយខោនធី។ បើអ្នកមានសំណួរអំពីថាតើអ្នកគួរចាប់ផ្តើមសំណុំរឿងខ្លួនអ្នកផ្ទាល់ ឬអត់ សូមទូរស័ព្ទទៅការិយាល័យសុខុមាលភាពខោនធី ឬការិយាល័យផ្តល់សេវាផ្នែកច្បាប់នៅតាមមូលដ្ឋាន។